# កំណត់ចំណាំអំពីសេវាកម្មគាំទ្រនៅតាមផ្ទះ (IHSS)

# ការដោះស្រាយបណ្តឹង IHSS

ក្នុងឆ្នាំ២០០៩ រដ្ឋកាលីហ្វ័រញ៉ាបានព្យាយាមកាត់បន្ថយសេវាកម្មគាំទ្រនៅតាមផ្ទះក្នុងមូលដ្ឋាន និងចំនួនម៉ោងដែលពាក់ព័ន្ធ។ ក្នុងឆ្នាំ២០១១ រដ្ឋកាលីហ្វ័រញ៉ាបានព្យាយាមកាត់បន្ថយចំនួនម៉ោងសេវាកម្មគាំទ្រនៅតាមផ្ទះចំនួន ២០ភាគរយ។ នៅឆ្នាំ២០០៩រដ្ឋព្យាយាមកាត់បន្ថយមូលនិធិសម្រាប់កម្មករដែលបម្រើការនៅតាមផ្ទះ ដែលរកចំណូលបានចំនួនជាង ៩,៥០ដុល្លារក្នុងមួយម៉ោង។

អ្នកទទួលសេវាកម្ម IHSS និងសហជីពកម្មករបានដាក់ពាក្យបណ្តឹង។ ពួកគេបានឈ្នះដីការបង្គាប់បណ្តោះអាសន្នឲ្យបញ្ឈប់ការកាត់បន្ថយចំនួនម៉ោងនេះ។ រដ្ឋកាលីហ្វ័រញ៉ាបានដាក់បណ្តឹងទៅសាលាឧទ្ធរណ៍។ គ្មាននរណាម្នាក់ដឹងថាតើតុលាការនឹងអនុញ្ញាតឲ្យកាត់បន្ថយចំនួនម៉ោង ឬយ៉ាងណានោះទេ។ បច្ចុប្បន្ន មានដំណោះស្រាយមួយ។ ប្រសិនបើតុលាការសម្រេចលើដំណោះស្រាយនោះ៖

- ការកាត់បន្ថយចំនួនម៉ោង ២០ភាគរយនឹងមិនមានទៀតទេ។ ការកាត់បន្ថយចំនួនម៉ោងនឹងធ្វើឡើងក្នុងមួយឆ្នាំម្តងក្នុងកម្រិត ៨ភាគរយ ដោយចាប់ផ្តើមពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៣ទៅ។ កម្រិត ៨ភាគរយនេះ

ខ្ពស់ជាងកម្រិតកាត់បន្ថយចំនួនម៉ោងបច្ចុប្បន្ន ៤,៤ភាគរយ ពីព្រោះការកាត់បន្ថយ ៣,៦ភាគរយធ្វើឡើងរួចហើយ ដែលការកាត់បន្ថយនេះមិនមែនជាផ្នែកមួយនៃពាក្យបណ្តឹងនេះទេ។

- ប្រហែលជានៅខែកក្កដា ឆ្នាំ២០១៤ ការកាត់បន្ថយចំនួនម៉ោងសេវាកម្ម IHSS នឹងធ្លាក់ចុះមកនៅត្រឹម ៧ភាគរយ (៣,៤ភាគរយលើកម្រិតដែលបានកាត់បន្ថយបច្ចុប្បន្ន ៣,៦ភាគរយ)។
- មូលនិធិរដ្ឋសម្រាប់ប្រាក់ឈ្នួលសេវាកម្ម IHSS នឹងមិនមាននោះទេ។
- លោកអ្នកអាចស្នើឲ្យរដ្ឋបន្ថែមចំនួនម៉ោងថែមទៀត ប្រសិនបើស្ថានភាពរបស់លោកអ្នកផ្លាស់ប្តូរ។

**ដើម្បីទទួលបានព័ត៌មានបន្ថែម ឬដាក់ពាក្យជំទាស់ទៅកាន់តុលាការ៖** លោកអ្នកអាចទទួលបានលិខិតថតចម្លងនៃកំណាត់ចំណាំនេះ និងកិច្ចព្រមព្រៀងដំណោះស្រាយពីការិយាល័យសុខុមាល ភាពរដ្ឋ ឬអាជ្ញាធរសាធារណៈរបស់លោកអ្នក។ ជាងនេះទៀត លោកអ្នកអាចទទួលបានព័ត៌មានលម្អិតនៅតាមគេហទំព័រខាងក្រោមនេះ៖

www.disabilityrightsca.org, www.altshulerberzon.com, www.dhcs.ca.gov និង www.dss.cahwnet.gov.

លោកអ្នកក៏អាចផ្ញើសារទៅកាន់មេធាវី ដែលតំណាងឲ្យអ្នកទទួលសេវាកម្ម IHSS តាមរយៈ 1-866-752-6679.

កាលបរិច្ឆេទកំណត់ក្នុងការជំទាស់ទៅនឹងដំណោះស្រាយត្រឹមថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៣

លោកអ្នកមិនត្រូវធ្វើអ្វីមួយនោះទេ ប្រសិនបើលោកអ្នកមិនបានប្តឹងជំទាស់ទៅនឹងដំណោះស្រាយនេះនោះ។